ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ០២

ត្រីមាសទី០១ ឆ្នាំ២០២២

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៩-១-២០២២ -ព្រះរាជក្រម នស/រកម/០១២២/០០៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី សហគ្រាសពាណិជ្ជកម្ម ១២៥


### ២~ព្រះរាជក្រឹត្យ


៥-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៧ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៨ រូប ១៣៨

៥-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៨ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ខួន មាស** ជាអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១៤០

៥-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៩ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **កខ សុខសាធី** ជារដ្ឋលេខាធិការក្រសួងផែនការ ១៤១

៥-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២០ ស្តីពី ការតម្លើងឋានៈឯកឧត្តម **ហេង សិទ្ធី** ទីប្រឹក្សា និងនាយករងខុទ្ទកាល័យឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន និងតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ២ រូប ១៤២

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២១ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **គឹម សៀប** ជានាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ១៤៣

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **នុត ឌុស្លា** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ ១៤៤

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៣ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ឃី កុសល** ជាអនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៤៥

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឧត្តមសេនីយ៍ទោ **ទៀ សីហា** នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ១៤៦

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន របួស ពិការ ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ត្រូវផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ២៨ រូប ១៤៧

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៦ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ៧៣ រូប ១៤៩

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៧ ស្តីពី ការផ្តល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **ប្រាក់ យីភាន** ភេទប្រុស ដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយ សម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ ១៥៣

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់គ្រួសារអ្នកស្រី **ហ៊ីបថុង ផាត់ថាម៉ានុន** **(HEEPTONG PATTAMANUN)** ជនជាតិថៃ សញ្ជាតិថៃ ដែលមានសមាជិក ៣ រូប ១៥៤

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០២៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ហ្គតខាងភ្លូ វ៉ូរ៉ាវីដ** **(GODKHANGPLU WORAWIT)** ជនជាតិថៃ សញ្ជាតិថៃ ១៥៥

៧-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០៣០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **ចាង ជា** **(ZHANG JIE)** ជនជាតិចិន សញ្ជាតិចិន ១៥៦

៨-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០៣១ ស្តីពី ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការ ១៨ រូប ១៥៧

៨-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០៣២ ស្តីពី ការអនុញ្ញាតលះបង់សញ្ជាតិខ្មែរដោយគ្មានការបង្ខិតបង្ខំដល់ លោកស្រី **សុខ ផល្លា** **(SOK PHALLA)** ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ ១៥៩

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

៤-១-២០២២ -អនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២៥៤ ហិកតា ៥៥ អា ១២ សង់ទីអា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគផ្ទៃដីទំហំ ១៥៩ ហិកតា ៨១ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងចំនួន ២៤០ គ្រួសារ និងរក្សាទុកផ្ទៃដីទំហំ ៩៤ ហិកតា ៧៤ អា ១២ សង់ទីអា ជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិកាំងមេម៉ាយ សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ១៦០

| | | |
|---|---|---|
| ៤-១-២០២២ | -អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពី ការកាត់ឆ្វៀលដីទំហំ ៩៣ ហិកតា ៦៣ អា ចេញពីតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិព្រះសីហនុ "រាម" កំណត់ដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ផ្តល់សិទ្ធិជាកម្មសិទ្ធិជូនអ្នកឧកញ៉ា **ឃុន សៀ** | ១៦៤ |
| ៥-១-២០២២ | -អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី ការបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញ | ១៦៧ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ១៧៦ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៨១ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៨២ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៨៤ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៨៥ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៨៧ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ២០ អនក្រ.តត ស្តីពី ការនិយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៨៩ |
| ៦-១-២០២២ | -អនុក្រឹត្យលេខ ២១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៩០ |
| ១០-១-២០២២ | -អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ១៩១ |
| ១៣-១-២០២២ | -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ១៩២ |
| ១៣-១-២០២២ | -អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ១៩៩ |


## ២~សេចក្តីសម្រេច


| | | |
|---|---|---|
| ២០-១-២០២២ | -សេចក្តីសម្រេចលេខ ០៤ សសរ ស្តីពី ការចាត់តាំងបន្ថែមសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ២០៨ |
| ២៨-១-២០២២ | -សេចក្តីសម្រេចលេខ ០៥ សសរ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម | ២១០ |


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១១-១-២០២២ | -ប្រកាសលេខ ០០៩ សហវ.ប្រក ស្តីពី ការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ | ២១៣ |

## ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


២៤-១-២០២២ -ប្រកាសលេខ ០១៦ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊្វូយគ័នហ្វេង ថេកណឡូជី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបង្គុំ និងគ្រឿងបំណែកទោចក្រយាន (កង់)គ្រប់ប្រភេទ ២១៦

២៤-១-២០២២ -ប្រកាសលេខ ០១៧ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនឃ្យុង វ៉ុនដាង អឺភែរឹល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ២១៩

២៤-១-២០២២ -ប្រកាសលេខ ០១៨ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីង ហឺ អ៊ី អេហ្គ្រីខល-ឈ័រ ឯ.ក បង្កើតរោងចក្រ កែច្នៃវេចខ្ចប់ផ្លែចេក ២២២

២៤-១-២០២២ -ប្រកាសលេខ ០១៩ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្លាញតិច (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ២២៥

២៤-១-២០២២ -ប្រកាសលេខ ០២០ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខូឡឹមបើស អឺភែរឹល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ២២៨

២៤-១-២០២២ -ប្រកាសលេខ ០២១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គ្រីស្ដាល់ ម៉ាទីន (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ២៣១

២៤-១-២០២២ -ប្រកាសលេខ ០២២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊្សឺបេន សេហ្វធី (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង ២៣៤

២៤-១-២០២២ -ប្រកាសលេខ ០២៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉្សាតា (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្លាកសញ្ញា (ពីក្រដាស, កំណាត់), ប្រដាសបិទ,ស្លាកសញ្ញា (បោះពុម្ព) និងថង់ប្លាស្ទិក ២៣៧

២៤-១-២០២២ -ប្រកាសលេខ ០២៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ អេធីធី ស៊ូ-ម៉េកឃើង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតស្បែកជើង ២៤០

២៤-១-២០២២ -ប្រកាសលេខ ០២៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សៀងហៃ សាន់វីន ហ្វឹសថេក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ស្រោមពូក ស្រោមខ្នើយ សម្លៀកបំពាក់សត្វចិញ្ចឹម និងសម្ភារៈសម្រាប់សត្វ ២៤៣

២៤-១-២០២២ -ប្រកាសលេខ ០២៦ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេសស៊ី វ៉ាំដូ ខឹមផូណិន (ខេមបូឌា) បង្កើតរោងចក្រ ផលិតគ្រឿងបង្គុំអេឡិកត្រូនិក និងគ្រឿងបង្គុំអគ្គិសនី ២៤៦

# ព្រះរាជក្រម

នស/រកម/០១២២/ ០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

## ស្តីពី

## វិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ .-**

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម៖

- ដោយធ្វើនិរាករណ៍ មាត្រា១៦៦ មាត្រា១៧៥ មាត្រា១៨២ មាត្រា១៨៣ មាត្រា១៨៤ មាត្រា១៨៥ មាត្រា១៨៦ មាត្រា១៨៧ មាត្រា១៨៨ មាត្រា១៨៩ មាត្រា១៩០ និងមាត្រា១៩៦

- ដោយកែប្រែ មាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៥៩ មាត្រា៦២ មាត្រា៨៧ មាត្រា១០១ មាត្រា១០៦ មាត្រា១១០ មាត្រា១១៤ មាត្រា១១៥ មាត្រា១៣៧ មាត្រា១៤៤ មាត្រា១៦១ មាត្រា១៧៤ មាត្រា១៩២ មាត្រា១៩៥ មាត្រា២២៥ មាត្រា២៣៤ មាត្រា២៥៥ មាត្រា២៦២ មាត្រា២៧០ និងមាត្រា២៧១ និងដោយកែប្រែជំពូកនិងផ្នែក ព្រមទាំងបន្ថែមមាត្រា៨ ស្ទួន មាត្រា៥៣ ស្ទួន ក្នុងជំពូកទី២ និងមាត្រា១៤៧ ស្ទួន ក្នុងជំពូកទី៣ ដូចតទៅ៖

**មាត្រា១ .- ថ្មី**

ច្បាប់នេះកំណត់ពីទម្រង់នៃសហគ្រាសពាណិជ្ជកម្មដែលជាសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនិងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

**មាត្រា២ .- ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១-**បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

២-**ពាណិជ្ជករ** សំដៅដល់បុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបររបស់ខ្លួនជាប្រចាំ។

៣-**មន្ត្រីចុះបញ្ជី** សំដៅដល់អ្នកទទួលចុះបញ្ជីដែលបានតែងតាំងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

៤-**ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម** សំដៅដល់ការិយាល័យដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។

៥-**បុត្រសម្ព័ន្ធ** សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនមួយផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ"។

៥.១-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានក្រុមហ៊ុនសហកម្មសិទ្ធិមេកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ។

៥.២-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនត្រូវបានក្រុមហ៊ុនមូលធនមេត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងបុត្រសម្ព័ន្ធនោះ។

៦-**លេខាធិការរបស់ក្រុមហ៊ុន** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុនមូលធន ហើយមានសិទ្ធិក្នុងការទទួលនិងរក្សាទុកឯកសារដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រុមហ៊ុន។

**មាត្រា៣ ._ ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមូលធន ត្រូវមានលេខាធិការរបស់ក្រុមហ៊ុនដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដនិងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា។

ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់លេខាធិការរបស់ក្រុមហ៊ុន ហើយលេខាធិការរបស់ក្រុមហ៊ុននោះត្រូវតែជារូបវន្តបុគ្គលដែលមានកាយសម្បទានិងសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ។ លេខាធិការរបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតផ្លូវការនិងឯកសារទាំងឡាយព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការ ក្នុងនាមក្រុមហ៊ុនមូលធននោះ។

សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ។ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីនិងការផ្លាស់ប្តូរលេខាធិការរបស់ក្រុមហ៊ុនក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ។

សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ._ ថ្មី**

ឯកសារនិងព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនមូលធនត្រូវប្រគល់ទៅឱ្យលេខាធិការរបស់ក្រុមហ៊ុននៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។

ឯកសារនិងព័ត៌មានត្រូវប្រគល់ទៅឱ្យម្ចាស់សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិក្នុងអំឡុងម៉ោងធ្វើការធម្មតា លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យសហកម្មសិទ្ធិករទូទៅបានក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ឯកសារនិងព័ត៌មានអាចប្រគល់ទៅឱ្យអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះត្រូវផ្ញើទៅឱ្យក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្ម។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីតាមគ្រប់មធ្យោបាយ ត្រូវបានចាត់ទុកថាជាការបញ្ជូនទៅសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធននោះ។

**មាត្រា៥ .‒ ថ្មី**

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនត្រូវប្រើនាមករណ៍ជាភាសាខ្មែរ។ នាមករណ៍ជាភាសាខ្មែរត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំស្មើនឹងពីរដងធំជាងភាសាដទៃទៀត ប្រសិនបើមាន។ ការបកប្រែន័យរបស់នាមករណ៍សហគ្រាសឯកបុគ្គល ឬក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់។ នាមករណ៍ជាភាសាខ្មែរនិងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា។

សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរនៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន។

## ជំពូកទី២ ថ្មី

## សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិ

### ផ្នែកទី១ ថ្មី

### សហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**ក (ថ្មី). ការបង្កើតសហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**

**មាត្រា៨ .‒ ស្ទួន**

សហគ្រាសឯកបុគ្គល គឺជាសហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។

ម្ចាស់សហគ្រាសឯកបុគ្គល គឺជាពាណិជ្ជករ។

សហគ្រាសឯកបុគ្គល ដែលស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

នាមករណ៍របស់សហគ្រាសឯកបុគ្គលត្រូវដាក់នូវពាក្យថា "សហគ្រាសឯកបុគ្គល" ឬសរសេរជាអក្សរកាត់ដាក់ខាងចុងឬខាងក្រោម។

កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់សហគ្រាសឯកបុគ្គល គឺជាការទទួលខុសត្រូវដោយផ្ទាល់និងដោយគ្មានកម្រិតលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសនោះ។ សហគ្រាសឯកបុគ្គលមិនតម្រូវឱ្យមានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ។ សហគ្រាសឯកបុគ្គលមិនមាននីតិបុគ្គលភាពឬគុណៈដាច់ដោយឡែកពីម្ចាស់សហគ្រាសឡើយ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ខ (ថ្មី). ការរំលាយ និងការជម្រះបញ្ជីសហគ្រាសឯកបុគ្គល និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### មាត្រា៥៣ .- ស្ទួន

ម្ចាស់សហគ្រាសឯកបុគ្គល អាចរំលាយសហគ្រាសរបស់ខ្លួនបាននៅពេលណាក៏បាន។

សហគ្រាសឯកបុគ្គល អាចត្រូវបានរំលាយដោយមូលហេតុដូចខាងក្រោម៖

- តាមការស្ម័គ្រចិត្ត
- មរណភាពរបស់ម្ចាស់សហគ្រាស
- សេចក្តីសម្រេចរបស់តុលាការ។

នីតិវិធីក្នុងការរំលាយសហគ្រាសឯកបុគ្គលតាមការស្ម័គ្រចិត្តឬមរណភាពរបស់ម្ចាស់សហគ្រាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយមានអនុលោមភាពតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា៥៩ .- ថ្មី

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅតាមទម្រង់បែបបទដែលបានកំណត់និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបោះពុម្ពឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀត ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

### មាត្រា៦២ .- ថ្មី

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរំលាយ រហូតដល់រយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ពីពេលដែលជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវ បញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះ តម្រូវឱ្យទុកជាភស្តុតាង។

### មាត្រា៨៧ .- ថ្មី

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទម្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១០១ .- ថ្មី**

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរលុះត្រាតែៈ

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្មនិងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី៥១(ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គលឬនីតិបុគ្គលសញ្ជាតិខ្មែរ ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម។

**មាត្រា១០៦ .- ថ្មី**

ក្រុមហ៊ុនឬបុគ្គលម្នាក់ដែលជានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោម ជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជន ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបានឡើយ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ឬបានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួនឬដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះៈ

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ។

គ-ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំងឬមិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តនិងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬលេខាធិការរបស់ក្រុមហ៊ុនណាម្នាក់មិនមានសុពលភាពឬមិនយកជាការបានឡើយ។

ច-ប្រាក់ខ្ចីនិងការធានា ឬការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ។

**មាត្រា១១០ .- ថ្មី**

ម្ចាស់ភាគហ៊ុននិងម្ចាស់បំណុលរបស់ក្រុមហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចពិនិត្យគ្រប់ឯកសារដូចដែលបានចែងនៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើ[illegible]បមិនគិតកម្រៃ។

[illegible]ក្រុមហ៊ុនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាច[illegible]ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប។

**មាត្រា១១៤ .- ថ្មី**

ក្រុមហ៊ុននិងលេខាធិការរបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទៀងទាត់ និងការពារឱ្យបានត្រឹមត្រូវ។

**មាត្រា១១៥ .- ថ្មី**

លិខិតស្នាមឬកិច្ចសន្យា ដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬអ្នកគ្រប់គ្រងម្នាក់ ឬលេខាធិការរបស់ក្រុមហ៊ុនម្នាក់ មានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ។

**មាត្រា១៣៧ .- ថ្មី**

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចណាមួយក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជា៖

ក-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចីឬកាតព្វកិច្ចទាំងឡាយដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុនឬដល់សាខាមួយរបស់ក្រុមហ៊ុន។

ខ-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួនដែលជាអភិបាល អ្នកគ្រប់គ្រង បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុនឬសាខាណាមួយរបស់ក្រុមហ៊ុន។

គ-កិច្ចសន្យាមួយធ្វើឡើងជាការរ៉ាប់រងសងការខូចខាតឬជាការធានា។

ឃ-កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ។

**មាត្រា១៤៤ .- ថ្មី**

ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នានិងរួមបញ្ចូលនូវសិទ្ធិ៖

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន។

២-ក្នុងការទទួលនូវរាល់ភាគលាភដែលបានប្រកាសដោយក្រុមហ៊ុន។

៣-ក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុននៅពេលមានការរំលាយ។

**មាត្រា១៤៧ .- ស្ទួន**

ម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនមូលធនដែលមិនមានបំណងបង្ហាញអត្តសញ្ញាណនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អាចតែងតាំងអ្នកតំណាងឱ្យឈរឈ្មោះជំនួសបាន។ ការតែងតាំងអ្នកតំណាង ត្រូវធ្វើឡើងតាមរយៈកិច្ចសន្យារវាងម្ចាស់ភាគហ៊ុននិងអ្នកតំណាង ដែលជារូបវន្តបុគ្គលឬនីតិបុគ្គល ហៅថាកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន។

ព័ត៌មានអំពីអត្តសញ្ញាណរបស់ម្ចាស់ភាគហ៊ុននិងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន ត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការតម្កល់ព័ត៌មាននិងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៦១ ._ ថ្មី**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងផ្នែកទី២នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

១-**អ្នកទិញដោយសុទ្ធចិត្ត** សំដៅដល់អ្នកទិញដែលបង់ថ្លៃឱ្យត្រឹមត្រូវ និងដោយមិនដឹងថាមានបណ្ដឹងទាមទារណាមួយ ហើយជាអ្នកដែលធ្វើការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ជាអ្នកកាន់កាប់ ឬជាអ្នកបញ្ជាដែលទទួលការផ្ទេរ ការកាន់កាប់មូលបត្រតាមទម្រង់ចុះបញ្ជីដែលបានបោះចេញឱ្យ។

២-**អ្នកជើងសា** សំដៅដល់បុគ្គលជាប់កាតព្វកិច្ចទាំងស្រុងឬមួយភាគនៃពេលវេលារបស់ខ្លួនក្នុងកិច្ចការជួញដូរមូលបត្រ និងជាអ្នកធ្វើសកម្មភាពជំនួសគេ ឬទិញមូលបត្រពីអតិថិជន ឬលក់មូលបត្រទៅឱ្យអតិថិជនក្នុងកិច្ចការជំនួញដែលជាប់ពាក់ព័ន្ធនោះ។

៣-ការប្រគល់ សំដៅដល់ការផ្ទេរការកាន់កាប់ដោយឆន្ទៈ។

៤-សុទ្ធ សំដៅដល់ពិតប្រាកដមិនក្លែងក្លាយឬក្លែងបន្លំ។

៥-ម្ចាស់មូលបត្រ សំដៅដល់បុគ្គលដែលកាន់កាប់មូលបត្រភាគហ៊ុនក្នុងលក្ខន្តិកៈក្រុមហ៊ុន ដែលត្រូវបានចេញដោយក្រុមហ៊ុនមូលធន។

៦-ចេញបន្ថែម សំដៅដល់ការចេញមូលបត្រលើសពីចំនួនអតិបរមានៃមូលបត្រ ដែលអ្នកចេញមូលបត្រត្រូវផ្ដល់សិទ្ធិតាមលក្ខន្តិកៈរបស់ខ្លួន ឬតាមកិច្ចសន្យាច្បាស់លាស់ក្នុងការចេញមូលបត្រ។

៧-អ្នកជាវ សំដៅដល់បុគ្គលដែលទាញរកចំណេញពីមូលបត្រដោយធ្វើការលក់ បញ្ចាំ ផ្ញើហ៊ីប៉ូតែក ចេញប័ណ្ណ ចេញប័ណ្ណសាជាថ្មី ធ្វើអំណោយនូវមូលបត្រនោះ ឬក៏ទាញរកចំណេញតាមកិច្ចការជំនួញណាមួយផ្សេងទៀតដោយឆន្ទៈ។

៨- មូលបត្រ សំដៅដល់លិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែលៈ

ក-ស្ថិតក្នុងទ្រង់ទ្រាយចុះបញ្ជី។

ខ-ជាគំរូប័ណ្ណមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬលើទីផ្សារមូលបត្រ ឬបានទទួលស្គាល់នៅក្នុងវិស័យណាមួយដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញឬត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ។

គ-ជាប្រភេទមួយឬស៊េរីមួយនៃមូលបត្រ ដែលចែកនៅក្នុងប្រភេទឬស៊េរីនៃលិខិតស្នាម។

ឃ-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែក ឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗ ក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន។

៩-ការផ្ទេរ សំដៅដល់ជាការផ្ទេរដែលរួមបញ្ចូលទាំងការបញ្ជូនឱ្យដោយប្រតិបត្តិតាមច្បាប់។

១០-គ្មានសិទ្ធិក្នុងការចុះហត្ថលេខា សំដៅដល់មនុស្សម្នាក់ប្រព្រឹត្តដោយគ្មានសិទ្ធិពិតប្រាកដ ហើយរួមទាំងការក្លែងបន្លំផង។

**មាត្រា១៧៤ ._ ថ្មី**

នៅក្នុងបណ្ដឹងពាក់ព័ន្ធលើមូលបត្រៈ

ក-រាល់ការចុះហត្ថលេខាលើមូលបត្រ ក្នុងករណីចាំបាច់គឺត្រូវបានទទួលស្គាល់ លើកលែងតែមានការប្រកែកជាក់លាក់។

ខ-ហត្ថលេខានៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវនិងមានការអនុញ្ញាត។ ប៉ុន្តែប្រសិនបើប្រការនៃភាពត្រឹមត្រូវនៃហត្ថលេខាត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុតាងគឺស្ថិតនៅលើភាគីប្ដឹងតវ៉ា។

គ-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវឬត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចម្លើយបង្ហាញភស្តុតាងផ្ទុយឬកង្វះខាតលើសុពលភាពនៃមូលបត្រនោះ។

ឃ-បើភាគីចុងចម្លើយលើកឡើងនូវភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយឬភាពមិនពេញលក្ខណៈនោះទៅវិញ។

**មាត្រា១៩២ .- ថ្មី**

ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវពីបុគ្គលណាមួយក្នុងមូលហេតុណាក៏ដោយរួមទាំងអសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែចំពោះអ្នកទិញដោយសុទ្ធចិត្តដើម្បី៖

១-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ។

២-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិដូចគ្នាទាំងអស់ឬមួយផ្នែក។

៣-ទាមទាររាល់ការខូចខាតទាំងឡាយ។

សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញដើម្បីរង់ចាំបណ្តឹងតវ៉ា។

**មាត្រា១៩៥ .- ថ្មី**

ពេលណាដែលមូលបត្រនៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិនោះក្នុងករណីដូចតទៅ៖

១-ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានអនុវត្ត។

២-ការផ្ទេរកម្មសិទ្ធិនោះគឺស្របតាមច្បាប់ឬផ្ទេរទៅឱ្យអ្នកជាពិតប្រាកដ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជី ការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួលខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ដែលកើតឡើងពីការពន្យារពេលមិនសមហេតុសមផលក្នុងការចុះបញ្ជី ឬពីការខកខាន ឬការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ។

**មាត្រា២២៥ .- ថ្មី**

ម្ចាស់ភាគហ៊ុន លេខាធិការរបស់ក្រុមហ៊ុន និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបានដោយមិនគិតថ្លៃ។

**មាត្រា២៣៤ .- ថ្មី**

សវនករត្រូវធ្វើការត្រួតពិនិត្យលើចំណុចដែលខ្លួនយល់ថាចាំបាច់ ដើម្បីរាយការណ៍ជូនម្ចាស់ភាគហ៊ុនទាំងឡាយលើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុនឬអភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមប្រឹក្សា បុគ្គលិក ឬលេខាធិការរបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មាន ការបកស្រាយបំភ្លឺ និងបញ្ជី

គណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ។

សវនកររបស់ក្រុមហ៊ុនមានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាតម្ចាស់ភាគហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករ ដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន។

ប្រសិនបើអភិបាលឬម្ចាស់ភាគហ៊ុន ទោះបីជាម្ចាស់ភាគហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្នឬសវនករពីមុនក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃមុនមហាសន្និបាត សវនករបច្ចុប្បន្នឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ។

**មាត្រា២៥៥ .– ថ្មី**

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវ៖

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន
- បំពេញកាតព្វកិច្ចទាំងឡាយ
- ធ្វើសកម្មភាពផ្សេងទៀតដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី
- តែងតាំងអ្នកជម្រះបញ្ជី។

អ្នកជម្រះបញ្ជីត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់ម្ចាស់ភាគហ៊ុន។ អ្នកជម្រះបញ្ជីត្រូវតែជាក្រុមហ៊ុនគណនេយ្យនិង/ឬសវនកម្ម ដែលទទួលបានអាជ្ញាប័ណ្ណពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយនិងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ទាំងកម្មសិទ្ធិជាសាច់ប្រាក់ឬជាវត្ថុទៅឱ្យម្ចាស់ភាគហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនដែលបានរំលាយ រយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំចាប់ពីកាលបរិច្ឆេទជម្រះបញ្ជីរួច។

**មាត្រា២៦២ .– ថ្មី**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬហេតុការណ៍ពិតដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ។

ក្នុងករណីចាំបាច់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឱ្យក្រុមហ៊ុនធ្វើបច្ចុប្បន្នកម្មនូវព័ត៌មានដែលបានចុះបញ្ជីឬដែលបានធ្វើប្រតិវេទន៍ប្រចាំឆ្នាំនៅគ្រប់កាលៈទេសៈ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុនមានសិទ្ធិចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារដែលបានធ្វើបច្ចុប្បន្នកម្មដល់ទីស្នាក់ការរបស់ក្រុមហ៊ុន និងតម្រូវឱ្យក្រុមហ៊ុនផ្ដល់ព័ត៌មានឬឯកសារបន្ថែម ដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មាននិងឯកសារ។

នីតិវិធីនៃការតម្រូវឱ្យក្រុមហ៊ុនធ្វើបច្ចុប្បន្នកម្មនូវព័ត៌មានដែលបានចុះបញ្ជីឬធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងការចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានឬឯកសារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៤ ថ្មី
## សាខាក្រុមហ៊ុនក្នុងស្រុកនិងក្រុមហ៊ុនពាណិជ្ជកម្មបរទេស

**មាត្រា២៧០ .- ថ្មី**

ក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធនដែលបានបង្កើតឡើងក្រោមច្បាប់នេះ អាចបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកមួយឬច្រើនបាន។ ក្រុមហ៊ុនដែលបង្កើតសាខា ត្រូវហៅថា "ក្រុមហ៊ុនដើម"។

សាខាក្រុមហ៊ុនក្នុងស្រុកគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

សាខាក្រុមហ៊ុនក្នុងស្រុកអាចធ្វើត្រឹមតែសកម្មភាពដែលមានចែងក្នុងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនដើមតែប៉ុណ្ណោះ។

ទ្រព្យសកម្មរបស់សាខាក្រុមហ៊ុនក្នុងស្រុកគឺជាទ្រព្យសកម្មរបស់ក្រុមហ៊ុនដើម។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើសកម្មភាពនិងកាតព្វកិច្ចរបស់សាខាក្រុមហ៊ុនក្នុងស្រុក។

សាខាក្រុមហ៊ុនក្នុងស្រុកត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូបឬច្រើនរូប ដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម។

នាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុកគឺជានាមករណ៍របស់ក្រុមហ៊ុនដើម។ នៅពីលើឬនៅពីមុខនាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុកនោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុនក្នុងស្រុក"។

សាខាក្រុមហ៊ុនក្នុងស្រុកអាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម ហើយក្រុមហ៊ុនដើមត្រូវស្នើសុំមកក្រសួងពាណិជ្ជកម្មដើម្បីលុបចេញពីបញ្ជីពាណិជ្ជកម្ម។

**មាត្រា២៧១ .- ថ្មី**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយមានទីតាំងធ្វើពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមានទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានតាមបែបបទផ្សេងៗ ដូចតទៅ៖

ក-ការិយាល័យតំណាងពាណិជ្ជកម្មឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម។

ខ-សាខាក្រុមហ៊ុនពាណិជ្ជកម្ម។

គ-បុត្រសម្ព័ន្ធ។

ការិយាល័យតំណាងពាណិជ្ជកម្មនិងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ១៤រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២២

ន សីហមុនី

៣រ៧.៤៤០១.០៥៧

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : ដាក់ឲ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ០៨រូប ៖

១- នាយឧត្តមសេនីយ៍ **សុខ ចំន្ទរិទ្ធី** អត្តលេខ ០៥៩២
២- ឧត្តមសេនីយ៍ទោ **តាន់ គីមបូរី** អត្តលេខ ០១៤០៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ឧត្តមសេនីយ៍ទោ **អ៊ុំ ម៉ូនី** អត្តលេខ ០២១៦៧

៤- ឧត្តមសេនីយ៍ត្រី **ឡិ ផាន់ណា** អត្តលេខ ០៣៩២១

៥- ឧត្តមសេនីយ៍ត្រី **ចាន់ សាធឿន** អត្តលេខ ០២០០៨

៦- ឧត្តមសេនីយ៍ត្រី **នេត្រ ចំណាន** អត្តលេខ ២០៤៥០

៧- ឧត្តមសេនីយ៍ត្រី **ស៊ិន ស៊ុម** អត្តលេខ ០៥៨៦២

៨- ឧត្តមសេនីយ៍ត្រី **ឯម សារិន** អត្តលេខ ០៧១៧៦ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ពរស.២២០១.០១៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២២*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងឯកឧត្តម **ឡុង មាស** ជាអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរល.០១២២.០១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២២*

[signature]

**នរោត្តម សីហមុនី**

បានយកសេចក្តីគោរពក្រាបបង្គំទូលថ្វាយ
ដើម្បីឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

[signature]

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានបញ្ចូលគ្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

[signature]

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០២៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងឯកឧត្តម **គង់ សុសាធី** ជារដ្ឋលេខាធិការក្រសួងផែនការ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

០១.០២៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២២*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០៤០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានៈឯកឧត្តម **ហេង សិទ្ធី** ទីប្រឹក្សានិងនាយករងខុទ្ទកាល័យឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២ :** តែងតាំងនិងផ្តល់ឋានៈជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ០២រូប :

១. ឯកឧត្តម **ឯម ច័ន្ទមិថឡ្យន៍** ជាទីប្រឹក្សានិងនាយករងខុទ្ទកាល័យ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២. ឯកឧត្តម **ឃុំ ធិត្យថិរិន្ទ្រ** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

រាកស.២៤០១.០៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២២

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **គឹម សៀប** ជានាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចារស. ២២០១.០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០២២*

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **នុត ធុត្តា** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តមសីហមុនី

៧៥៧. ៧៧០១. ០៧៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងមុខតំណែងឯកឧត្តម **ឃី កុសល** ជាអនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នសីហមុនី

៣៩ណ. ២២០១. ០២៣

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០២២

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់ ឧត្តមសេនីយ៍ទោ **ឡៅ សីហា** អត្តលេខ ០១៩៨៦៤ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ចាខស. ២២០១. ០២៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

**យើង**

នស/រកត/០១២២/ ០៧៥

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ នាយទាហាន របូស ពិការ ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ត្រូវផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក :**

១-ឧត្តមសេនីយ៍ទោ **ចាន់ សារិន** អត្តលេខ ០០១៤៧៧
២-ឧត្តមសេនីយ៍ទោ **ឃុន ឡេងឌី** អត្តលេខ ០០៨៥៨៧
៣-ឧត្តមសេនីយ៍ទោ **ម៉ី ធរះជេដ្ឋ** អត្តលេខ ០២៥០២៧
៤-ឧត្តមសេនីយ៍ទោ **គីម សិរីវឌ្ឍន៍** អត្តលេខ ០០១៦៥៩
៥-ឧត្តមសេនីយ៍ទោ **ហ៊ីម ផល្លី** អត្តលេខ ០១៧៥១៨
៦-ឧត្តមសេនីយ៍ទោ **ឃិន សុផាត** អត្តលេខ ០២២៣១៨
៧-ឧត្តមសេនីយ៍ទោ **សរ ស៊ីថា** អត្តលេខ ១៦០០៤០
៨-ឧត្តមសេនីយ៍ទោ **ទូច ចាន់លី** អត្តលេខ ០០៩៦៣៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ :**

១-ឧត្តមសេនីយ៍ត្រី **ឡុច ទិចិត្រ** អត្តលេខ ០០១៤៥៧

២-ឧត្តមសេនីយ៍ត្រី **គង់ សោភ័ណ្ឌ** អត្តលេខ ០០៨៤៥៧

៣-ឧត្តមសេនីយ៍ត្រី **អ៊ុក សាន្ត** អត្តលេខ ០១៧០១១

៤-ឧត្តមសេនីយ៍ត្រី **ណាក សាលី** អត្តលេខ ០០៩៤៦៤

៥-ឧត្តមសេនីយ៍ត្រី **គង់ ពៅ** អត្តលេខ ០១៣៨៤២

៦-ឧត្តមសេនីយ៍ត្រី **អ៊ុំ សុខុន** អត្តលេខ ០១០១៧៨

៧-ឧត្តមសេនីយ៍ត្រី **អ៊ុំ មុនី** អត្តលេខ ០១៤៥០២

៨-ឧត្តមសេនីយ៍ត្រី **នង សារ៉ាមី** អត្តលេខ ០០៨៥០២

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី :**

១-វរសេនីយ៍ឯក **គៀន បទុម** អត្តលេខ ០១៤០០៣

២-វរសេនីយ៍ឯក **សិរិទ្ធ មុន្នី** អត្តលេខ ០០១៧០៣

៣-វរសេនីយ៍ឯក **កង ណូរ៉ា** អត្តលេខ ០០៨៣៦៧

៤-វរសេនីយ៍ឯក **ប្លុង មុំរ៉ា** អត្តលេខ ០០៨៤៤៨

៥-វរសេនីយ៍ឯក **ចាន់ សុគន្ធ** អត្តលេខ ០០៨៥៩៤

៦-វរសេនីយ៍ឯក **ចាន់ សារ៉េត** អត្តលេខ ០១៤០៥០

៧-វរសេនីយ៍ឯក **ហុក សារុំ** អត្តលេខ ០៥៧៦២៥

៨-វរសេនីយ៍ឯក **ផាត់ ប៊ុណ្ណារ** អត្តលេខ ០២៥១២៩

៩-វរសេនីយ៍ឯក **ពីង ហេង** អត្តលេខ ០២៥១៣២

១០-វរសេនីយ៍ឯក **ឱម ស៊ីឡុ** អត្តលេខ ០០៨៨៣៤

១១-វរសេនីយ៍ឯក **សយ គឹមសាន** អត្តលេខ ០០៨២៨២

១២-វរសេនីយ៍ឯក **ណុប ឌុទ្ធី** អត្តលេខ ០២៧៥៧០

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ពាខស. ៧៤០១. ០៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២

ទសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ជាក់ឲ្យចូលនិវត្តន៍ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៖

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | **យឹម សាទី** | អត្តលេខ០០០០៧៧ |
| ២-ឧត្តមសេនីយ៍ឯក | **លី ឃីម៉ុន** | អត្តលេខ០០០០៨៣ |
| ៣-ឧត្តមសេនីយ៍ឯក | **ខាត់ ធីន** | អត្តលេខ០០០២១៣ |
| ៤-ឧត្តមសេនីយ៍ឯក | **ម៉ា សាឌួន** | អត្តលេខ០០០៣១៩ |
| ៥-ឧត្តមសេនីយ៍ឯក | **ឆ្វ សារ៉ុម** | អត្តលេខ០០០៣៣២ |
| ៦-ឧត្តមសេនីយ៍ឯក | **ហ៊ុំ ចយ** | អត្តលេខ០០០៣៥៤ |
| ៧-ឧត្តមសេនីយ៍ឯក | **អ៊ុត សាខន** | អត្តលេខ០០០៣៧៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

| | | |
|---|---|---|
| ៨-ឧត្តមសេនីយ៍ឯក | គង់ សារី | អត្តលេខ០០០៥៣៩ |
| ៩-ឧត្តមសេនីយ៍ឯក | ជ័យ ខេង | អត្តលេខ០០០៥៦៦ |
| ១០-ឧត្តមសេនីយ៍ឯក | ហាស ឈឿន | អត្តលេខ០០០៥៨៦ |
| ១១-ឧត្តមសេនីយ៍ឯក | ស៊ឹម សុភាព | អត្តលេខ០០០៦០៥ |
| ១២-ឧត្តមសេនីយ៍ឯក | ឃួន ឡិច | អត្តលេខ០០០៧៣៤ |
| ១៣-ឧត្តមសេនីយ៍ឯក | ស៊ីវខាំ ចាន់តារ៉ុង | អត្តលេខ០០១១៦៦ |
| ១៤-ឧត្តមសេនីយ៍ឯក | រស់ សុផាត | អត្តលេខ០០១៣៨៨ |
| ១៥-ឧត្តមសេនីយ៍ឯក | ភា សិទ្ធ | អត្តលេខ០០១៦២៣ |
| ១៦-ឧត្តមសេនីយ៍ឯក | សាំង អូន | អត្តលេខ០០១៦២៤ |
| ១៧-ឧត្តមសេនីយ៍ឯក | ព្រុំ ឌឹក | អត្តលេខ០០១៦៤១ |
| ១៨-ឧត្តមសេនីយ៍ឯក | ជា វាសនា | អត្តលេខ០០៣២១០ |
| ១៩-ឧត្តមសេនីយ៍ឯក | សីុទ្ធ គីរី | អត្តលេខ០០៤២៨៨ |
| ២០-ឧត្តមសេនីយ៍ទោ | ហាស ដែន | អត្តលេខ០០០២៤៩ |
| ២១-ឧត្តមសេនីយ៍ទោ | ភង សុឃួន | អត្តលេខ០០០៥២៨ |
| ២២-ឧត្តមសេនីយ៍ទោ | ដួង ស៊ីណា | អត្តលេខ០០០៥៥៣ |
| ២៣-ឧត្តមសេនីយ៍ទោ | អ៊ូ សំអុល | អត្តលេខ០០០៥៧៣ |
| ២៤-ឧត្តមសេនីយ៍ទោ | អ៊ុំម សុផុន | អត្តលេខ០០០៥៧៦ |
| ២៥-ឧត្តមសេនីយ៍ទោ | ឡាំ សេងវន្ត | អត្តលេខ០០០៦៧០ |
| ២៦-ឧត្តមសេនីយ៍ទោ | ពុទ្ធិ សំអាឡ៍ | អត្តលេខ០០០៧០៧ |
| ២៧-ឧត្តមសេនីយ៍ទោ | វន ណារិទ្ធសម្បត្តិ | អត្តលេខ០០១៣៨៤ |
| ២៨-ឧត្តមសេនីយ៍ទោ | ថោង វាសនា | អត្តលេខ០០១៤២៤ |
| ២៩-ឧត្តមសេនីយ៍ទោ | សឹង សុខុម | អត្តលេខ០០១៤៧៨ |
| ៣០-ឧត្តមសេនីយ៍ទោ | សៅ សឿន | អត្តលេខ០០១៥៨២ |
| ៣១-ឧត្តមសេនីយ៍ទោ | សេត ម៉ានី | អត្តលេខ០០១៥៨៥ |
| ៣២-ឧត្តមសេនីយ៍ទោ | កែវ តារា | អត្តលេខ០០១៧៤២ |
| ៣៣-ឧត្តមសេនីយ៍ទោ | ជុំ សារ៉ាត់ | អត្តលេខ០០១៧៨៣ |
| ៣៤-ឧត្តមសេនីយ៍ទោ | នង មណី | អត្តលេខ០០១៩៦៣ |
| ៣៥-ឧត្តមសេនីយ៍ទោ | ស៊ិន សេន | អត្តលេខ០០៣០៤៥ |
| ៣៦-ឧត្តមសេនីយ៍ទោ | ឯក សំអាន | អត្តលេខ០០៣១៤៧ |
| ៣៧-ឧត្តមសេនីយ៍ទោ | ជា សាវី | អត្តលេខ០០៤១២១ |
| ៣៨-ឧត្តមសេនីយ៍ទោ | ឌុល សារឿន | អត្តលេខ០០៤៣២៤ |
| ៣៩-ឧត្តមសេនីយ៍ទោ | សាំង គង់ | អត្តលេខ០០៤៣២៥ |

| | | |
|---|---|---|
| ៤០-ឧត្តមសេនីយ៍ទោ | នរោត្តម វីត្ថារ៉ូ | អត្តលេខ២០០៤៣៧៧ |
| ៤១-ឧត្តមសេនីយ៍ទោ | ជា វិសុធា | អត្តលេខ២០០៨៦៨៦ |
| ៤២-ឧត្តមសេនីយ៍ទោ | មាស សាវ៉ាត | អត្តលេខ២០០៩៦១៧ |
| ៤៣-ឧត្តមសេនីយ៍ទោ | ពោជ ខេម | អត្តលេខ២០១៣៦៩៧ |
| ៤៤-ឧត្តមសេនីយ៍ទោ | ឡូន សុផាត | អត្តលេខ២០១៣៨៤៨ |
| ៤៥-ឧត្តមសេនីយ៍ទោ | ពិន ពៅ | អត្តលេខ២០១៣៨៩៩ |
| ៤៦-ឧត្តមសេនីយ៍ទោ | ជ័យ សារុន | អត្តលេខ២០១៦០៧៩ |
| ៤៧-ឧត្តមសេនីយ៍ទោ | ស៊ិន ម៉ុនថន | អត្តលេខ២០១៦៧៦៩ |
| ៤៨-ឧត្តមសេនីយ៍ត្រី | ញ៉ឹក ម៉ុនឡី | អត្តលេខ២០០០២៣១ |
| ៤៩-ឧត្តមសេនីយ៍ត្រី | នន សាមី | អត្តលេខ២០០១៦៤៦ |
| ៥០-ឧត្តមសេនីយ៍ត្រី | អ៊ុំ សាមឿន | អត្តលេខ២០០២២៦៥ |
| ៥១-ឧត្តមសេនីយ៍ត្រី | នួម សេរី | អត្តលេខ២០០៨៥៤៩ |
| ៥២-ឧត្តមសេនីយ៍ត្រី | ទូច ស៊ីថា | អត្តលេខ២០០៩០៦០ |
| ៥៣-ឧត្តមសេនីយ៍ត្រី | ហ៊ិន សោម | អត្តលេខ២០០៩៥៩៩ |
| ៥៤-ឧត្តមសេនីយ៍ត្រី | កែម ហៃ | អត្តលេខ២០១៣៨៦៦ |
| ៥៥-ឧត្តមសេនីយ៍ត្រី | សៀប សារួន | អត្តលេខ២០១៣៨៦៨ |
| ៥៦-ឧត្តមសេនីយ៍ត្រី | អ៊ុយ យ៉ុន | អត្តលេខ២០១៣៨៧៦ |
| ៥៧-ឧត្តមសេនីយ៍ត្រី | ឯក ឥន្ទ្រី | អត្តលេខ២០១៣៨៩៥ |
| ៥៨-ឧត្តមសេនីយ៍ត្រី | រ័ត្ន ផល្លា | អត្តលេខ២០១៤០៤០ |
| ៥៩-ឧត្តមសេនីយ៍ត្រី | ស៊ឹន ពោធិ៍ផល | អត្តលេខ២០១៤០៤៦ |
| ៦០-ឧត្តមសេនីយ៍ត្រី | អ៊ិត ហោ | អត្តលេខ២០១៤០៨៣ |
| ៦១-ឧត្តមសេនីយ៍ត្រី | ខាយ សារ៉ាន | អត្តលេខ២០១៤២៥៣ |
| ៦២-ឧត្តមសេនីយ៍ត្រី | ម៉ុន សំអុល | អត្តលេខ២០១៧៥០៧ |
| ៦៣-ឧត្តមសេនីយ៍ត្រី | អ៊ុំ សារ៉ាត់ | អត្តលេខ២០១៧៨០៤ |
| ៦៤-ឧត្តមសេនីយ៍ត្រី | ស៊ឹន ឡាយ | អត្តលេខ២០១៩៩៧៤ |
| ៦៥-ឧត្តមសេនីយ៍ត្រី | នឿន វិញ | អត្តលេខ២០២៣៩៥២ |
| ៦៦-ឧត្តមសេនីយ៍ត្រី | នូ ឃឿន | អត្តលេខ២០២៤៧០៧ |
| ៦៧-ឧត្តមសេនីយ៍ត្រី | ពេជ្រ សម្បត្តិ | អត្តលេខ២០២៦៧១៣ |
| ៦៨-ឧត្តមសេនីយ៍ត្រី | ម៉ន់ សំអាន | អត្តលេខ២០៣១៥៦៩ |
| ៦៩-ឧត្តមសេនីយ៍ត្រី | សុភ សុមេធី | អត្តលេខ២០៣១៥៧២ |
| ៧០-ឧត្តមសេនីយ៍ត្រី | ទាល់ ឡាវី | អត្តលេខ២០៣១៧៨៩ |
| ៧១-ឧត្តមសេនីយ៍ត្រី | ណុប ថេត | អត្តលេខ២០៣៥១០៨ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧២-ឧត្តមសេនីយ៍ត្រី **តែ យ៉ាត** អត្តលេខ០៣៩៦៥៩

៧៣-ឧត្តមសេនីយ៍ត្រី **អ៊ុំ ហារី** អត្តលេខ១៧៩៨៤៨

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៩២៧.២២០១.០២៦

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០២២*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០២៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ **ប្រាក់ យីកាន** ភេទ ប្រុស កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៤ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឱ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចារសោ. ២២០១.០២៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០៦៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់គ្រួសារអ្នកស្រី **ហ៊ីបថុង ផាត់ថាម៉ានុន** ដែលមានសមាជិកៈ
១. អ្នកស្រី **ហ៊ីបថុង ផាត់ថាម៉ានុន** (HEEPTONG PATTAMANUN) ជនជាតិ ថៃ សញ្ជាតិ ថៃ កើតនៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៩១ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ (ជាម្ដាយ)។
២. កុមារា **វ៉ះសិទនិធិវ៉ាត់ ថាម** (VASITNITIWAT THAM) ជនជាតិ ថៃ សញ្ជាតិ ថៃ កើតនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ (ជាកូន)។
៣. កុមារា **វ៉ះសិទនិធិវ៉ាត់ មែក** (VASITNITIWAT MEK) ជនជាតិ ថៃ សញ្ជាតិ ថៃ កើតនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ (ជាកូន)។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នរោត្តម សីហមុនី (ហត្ថលេខា)

ចារល. ៦៦០១.០៦៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានយកទូលថ្វាយឡាយព្រះហស្ថលេខា
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

(ហត្ថលេខា)

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០៧៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ហ្គតខាងភ្លូ វ៉ូរ៉ាវីដ** (GODKHANGPLU WORAWIT) ជនជាតិ ថៃ សញ្ជាតិ ថៃ កើតនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៣ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

៣៥៨៦. ៧៧០១. ០៧៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានបង្ហាញត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០៣០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោកស្រី **ចាង ជា** (ZHANG JIE) ជនជាតិ **ចិន** សញ្ជាតិ **ចិន** កើតនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៨៥ នៅខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

៣១៧. ៤២០១. ០៣០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០៣១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការ ១៨រូប :

| | | | |
|---|---|---|---|
| ១. លោក | **ឌី សុខខេម** | តាំងស៊ប់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១ |
| ២. លោក | **តាំង ម៉េងឆុង** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ៣. លោក | **ស្រ៊ុន ហុកវៃ** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ៤. លោក | **ង ច័ន្ទតារា** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | |
|---|---|---|
| ៥. លោក | **កៅ សុម៉ាឡេត** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ៦. លោក | **ព្រំ ចន្ទន៍រដ្ឋា** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ៧. លោកស្រី | **ធិត ស៊ីណាត** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ៨. លោក | **ធីន សុខលីម** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ៩. លោកស្រី | **តាកេត ស័កដា** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១០. លោក | **តាព សុត័ត្រា** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១១. លោក | **យ៉ែម ជានិច្ច** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១២. លោក | **មេន ពុទ្ធារោ** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១៣. លោក | **សន រតនៈ** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១៤. លោក | **រៀម នររក្ស** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១៥. លោកស្រី | **លឹម សុផាន់ម៉ៃ** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១៦. លោក | **ពៅ ឧត្តម** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១៧. លោកស្រី | **រ៉េន ស្រីរ័ត្ន** | តាំងស៊ប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ |
| ១៨. លោក | **ប៉ុក ម៉េង** | តាំងស៊ប់ថ្ងៃទី១ ខែសីហា ឆ្នាំ២០២១។ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត. ០២២០១.០៣១

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០២២*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** អនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរដោយគ្មានការបង្ខិតបង្ខំដល់ លោកស្រី **សុខ ផល្លា (SOK PHALLA)** ជនជាតិខ្មែរ សញ្ជាតិ ខ្មែរ កើតនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៦៨ ទីកន្លែងកំណើតខេត្តតាកែវ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរក. ៦៦០១. ០៣៦

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០២២*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ផ្ទៃដីទំហំ ២៥៤ ហិកតា ៥៥ អា ១២ សង់ទីអា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគផ្ទៃដីទំហំ ១៥៩ ហិកតា ៨១ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ចំនួន ២៤០ គ្រួសារ និងរក្សាទុកផ្ទៃដីទំហំ ៩៤ ហិកតា ៧៤ អា ១២ សង់ទីអា ជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិកាំងមេម៉ាយ សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីទំហំ ២៥៤ ហិកតា ៥៥ អា ១២ សង់ទីអា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគផ្ទៃដីទំហំ ១៥៩ ហិកតា ៨១ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង និងរក្សាទុកផ្ទៃដីទំហំ ៩៤ ហិកតា ៧៤ អា ១២ សង់ទីអា ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិកាំងមេម៉ាយ សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្ទឹងត្រែង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៤០ គ្រួសារ ស្ថិតនៅភូមិកាំងមេម៉ាយ សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**មាត្រា៣ .-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ២៦១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២៤០ គ្រួសារ ស្ថិតនៅភូមិកាំងមេម៉ាយ សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ឆ្វៀលដីទំហំ ៩៣ ហិកតា ៦៣ អា ចេញពីតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិព្រះសីហនុ "រាម" កំណត់ដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ផ្តល់សិទ្ធិជាកម្មសិទ្ធិជូនអ្នកឧកញ៉ា ឃុន សៀ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់តំបន់ប្រើប្រាស់ដោយចីរភាពលើផ្ទៃដីទំហំ ៣ ៣០០ ហិកតា ក្នុងឧទ្យានជាតិព្រះសីហនុ "រាម" និងធ្វើអនុបយោគដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ ._**

កាត់ឆ្វៀលដីទំហំ ៩៣ ហិកតា ៦៣ អា ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញពីតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិព្រះសីហនុ "រាម" កំណត់ដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី



Ж|

២៣ ខែមិថុនា ឆ្នាំ២០០៨ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីទំហំ ៩៣ ហិកតា ៦៣ អា ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជូនអ្នកឧកញ៉ា ឃុន សៀ។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ២កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..០២៤ អនក្រ.បក..ចុះថ្ងៃទី..២៤.....ខែ..មករា..ឆ្នាំ២០២២..




តារាងនិយាមកាចំណុចព្រំដី

Projection UTM Zone 48N. Datum WGS 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 357470.783 | 1164373.231 | 32 | 356572.660 | 1162291.308 |
| 2 | 357471.793 | 1163771.769 | 33 | 356588.150 | 1162274.784 |
| 3 | 357315.173 | 1163760.810 | 34 | 356593.996 | 1162257.907 |
| 4 | 357246.221 | 1163753.831 | 35 | 356595.311 | 1162234.666 |
| 5 | 357244.446 | 1164373.225 | 36 | 356590.880 | 1162201.325 |
| 6 | 357939.660 | 1162346.759 | 37 | 356578.900 | 1162142.267 |
| 7 | 357972.606 | 1162116.130 | 38 | 356573.951 | 1162124.433 |
| 8 | 357967.347 | 1162114.975 | 39 | 356485.630 | 1161972.520 |
| 9 | 357970.941 | 1162093.267 | 40 | 356389.153 | 1161990.565 |
| 10 | 357993.458 | 1161957.271 | 41 | 356272.580 | 1162000.695 |
| 11 | 358006.885 | 1161876.179 | 42 | 356262.475 | 1162578.830 |
| 12 | 357905.212 | 1161896.514 | 43 | 355914.680 | 1162726.990 |
| 13 | 357893.703 | 1161891.357 | 44 | 355976.170 | 1162683.300 |
| 14 | 357871.741 | 1161894.681 | 45 | 356099.200 | 1162632.640 |
| 15 | 357856.978 | 1161957.271 | 46 | 356099.200 | 1162015.737 |
| 16 | 357835.008 | 1162042.436 | 47 | 355912.510 | 1162029.450 |
| 17 | 357821.479 | 1162078.648 | 48 | 355756.930 | 1162033.031 |
| 18 | 357811.907 | 1162145.937 | 49 | 355559.286 | 1162025.490 |
| 19 | 357798.975 | 1162190.334 | 50 | 355466.074 | 1162016.495 |
| 20 | 357763.305 | 1162295.491 | 51 | 355353.307 | 1162000.879 |
| 21 | 357759.532 | 1162312.575 | 52 | 355299.005 | 1161986.074 |
| 22 | 356463.572 | 1162576.486 | 53 | 355311.052 | 1162726.989 |
| 23 | 356451.914 | 1162546.997 | 54 | 354881.050 | 1161914.446 |
| 24 | 356445.591 | 1162524.648 | 55 | 355032.505 | 1161840.066 |
| 25 | 356446.689 | 1162510.805 | 56 | 355003.263 | 1161813.162 |
| 26 | 356456.751 | 1162479.508 | 57 | 354909.907 | 1161708.324 |
| 27 | 356471.721 | 1162440.364 | 58 | 354873.434 | 1161738.701 |
| 28 | 356482.440 | 1162402.274 | 59 | 354771.451 | 1161758.159 |
| 29 | 356491.463 | 1162363.850 | 60 | 354752.875 | 1161765.306 |
| 30 | 356512.540 | 1162326.213 | 61 | 354786.946 | 1161829.252 |
| 31 | 356523.588 | 1162316.069 | 62 | 354832.269 | 1161869.960 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើត "**សហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ**" ដែលសរសេរជាអក្សរកាត់ថា **ស.ស.ភ.** និងមានឈ្មោះជាភាសាអង់គ្លេសថា Enterprise for Managing Municipal Solid Waste in Phnom Penh ដែលសរសេរជាអក្សរកាត់ថា EWP ដើម្បីជំនួសរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ ដែលស្ថិតនៅក្រោមរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានីភ្នំពេញ។

**ស.ស.ភ.** ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់រដ្ឋបាលរាជធានីភ្នំពេញ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២ ._**

**ស.ស.ត.** ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាសហគ្រាសពាណិជ្ជកម្ម និងមានស្វ័យភាពបរិប្បូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។

**ជំពូកទី ២**

**បេសកកម្ម តួនាទី និងភារកិច្ច**

**មាត្រា ៣ ._**

**ស.ស.ត.** មានបេសកកម្មគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយសោភ័ណភាព ចីរភាព និងសុខុមាលភាព។

**មាត្រា ៤ ._**

**ស.ស.ត.** មានភារកិច្ច ដូចតទៅ÷

- ពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីធ្វើឱ្យប្រសើរឡើងផ្នែកសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- សហការ និងរៀបចំនីតិវិធីដេញថ្លៃដែលមានលក្ខណៈប្រកួតប្រជែង និងកិច្ចសន្យានានា ដើម្បីជ្រើសរើសក្រុមហ៊ុនដៃគូដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន
- ចុះកិច្ចសន្យាជាមួយប្រតិបត្តិករផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ និងសេវាករដទៃទៀត ក្នុងន័យបម្រើប្រយោជន៍ដល់ប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ
- រៀបចំប្រព័ន្ធប្រមូល និងបង់ចំណូលសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន តាមប្រព័ន្ធទូទាត់ស្វ័យប្រវត្តិកម្ម (Automatic Billing System) ដើម្បីធានាប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព
- ទូទាត់កម្រៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដល់ប្រតិបត្តិករដែលបានផ្តល់សេវា
- រៀបចំតារាងកម្រៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ស្របតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង

- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន របស់ប្រតិបត្តិករ ព្រមទាំងណែនាំប្រតិបត្តិករក្នុងការបំពាក់មធ្យោបាយ គ្រឿងចក្រ ឧបករណ៍ពាក់ព័ន្ធនានាក្នុងការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ស្របតាមកិច្ចសន្យា
- គ្រប់គ្រងការសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់កម្ទេចថ្ម ដី សំណល់គ្រឿងបរិក្ខារសង្ហារឹមចាស់ៗ សំណល់សួនច្បារ សំណល់មែកឈើ ដែលមិនមែនជាសំណល់គ្រោះថ្នាក់
- សហការជាមួយប្រតិបត្តិករផ្តល់សេវា និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីអនុវត្តវិធានការច្បាប់ និងវិធានការអប់រំ ផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ពាក់ព័ន្ធគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក៏ដូចជាសេចក្តីណែនាំ និងកម្មវិធីនៃការផ្តល់សេវា
- ធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពការងារសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន
- សហការជាមួយសហគ្រាសគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង ដើម្បីទទួលបាននូវទិន្នន័យបរិមាណសំរាម សម្រាប់ធ្វើការទូទាត់ជូនប្រតិបត្តិករ
- សហការ សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ដើម្បីទទួលបានធាតុចូលក្នុងការកែលម្អប្រព័ន្ធទូទាត់ ប្រព័ន្ធប្រមូលចំណូល និងការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន

បំពេញភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញពីអាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ ឬតាមការចាំបាច់។

**មាត្រា ៥ ._**

**ស.ស.ត.** ជានីតិបុគ្គលដែលមានបុគ្គលភាពគតិយុត្តពេញលេញស្របតាមច្បាប់កំណត់ ក្នុងកិច្ចប្រតិបត្តិការអាជីវកម្ម និងការផ្តល់សេវាកម្មរបស់ខ្លួន ហើយមានសិទ្ធិពេញលេញតាមផ្លូវច្បាប់ក្នុងការកាន់កាប់ ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា ៦ ._**

ទីស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ **ស.ស.ត.** ស្ថិតនៅសាលារាជធានីភ្នំពេញ អាគារលេខ៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងអាចកំណត់និង/ឬផ្លាស់ប្តូរទីស្នាក់ការកណ្តាលរបស់ខ្លួនបាន តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

## ជំពូកទី ៣
## ការដឹកនាំ និងគ្រប់គ្រង

**មាត្រា ៧ ._**

**ស.ស.ត.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ៧ (ប្រាំពីរ) រូប ដែលមានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| - អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | ១ រូប | ប្រធាន |
| - តំណាងក្រសួងមហាផ្ទៃ | ១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - តំណាងក្រសួងរ៉ែ និងថាមពល | ១ រូប | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | ១ រូប | សមាជិក |
| - អគ្គនាយក **ស.ស.ត.** | ១ រូប | សមាជិក |
| - តំណាងបុគ្គលិករបស់**ស.ស.ត.** | ១ រូប | សមាជិក |

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពពីវិស័យសាធារណៈ លើកលែងតែតំណាងបុគ្គលិក ត្រូវតែងតាំងសម្រាប់អាណត្តិ៣ (បី)ឆ្នាំ ហើយអាចបន្តជាថ្មីទៀតបាន ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីទទួលបានការស្នើសុំពី អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។

តំណាងបុគ្គលិក ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិករបស់ **ស.ស.ត.**។

សមាសភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់មុនអាណត្តិ តាមសំណើរបស់ក្រសួង-ស្ថាប័នតំណាង ក្នុងករណីសមាជិកក្រុមប្រឹក្សាភិបាល មានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង-ស្ថាប័ន ឬតំណាងបុគ្គលិករបស់ **ស.ស.ត.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

**មាត្រា ៨ ._**

អាណាព្យាបាលបច្ចេកទេស ត្រូវទទួលខុសត្រូវក្នុងការបំពេញទម្រង់បែបបទនានានៃការបង្កើត **ស.ស.ត.** ដែលមានជាអាទិ៍÷

- រៀបចំលក្ខន្តិកៈសហគ្រាសរបស់ **ស.ស.ត.** ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំលក្ខន្តិកៈបុគ្គលិក
- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- បំពេញទម្រង់បែបបទទាំងអស់ស្របតាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។



៥

**មាត្រា ៩ ._**

ការងារប្រចាំថ្ងៃរបស់ **ស.ស.ត.** ត្រូវដឹកនាំដោយ **អគ្គនាយក** ១រូប ដែលត្រូវបានជ្រើសរើសចេញពីវិស័យសាធារណៈ ឬវិស័យឯកជន ដោយឈរលើគោលការណ៍នៃការប្រកួតប្រជែង បើកចំហ និងតម្លាភាព ផ្អែកលើសមត្ថភាព និងបទពិសោធន៍ក្នុងវិស័យធុរកិច្ច ឬវិស័យគ្រប់គ្រងបរិស្ថាន ឬរដ្ឋបាល។ អគ្គនាយក **ស.ស.ត.** ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីទទួលបានការស្នើសុំពី អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។

**មាត្រា ១០ ._**

ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងភារកិច្ចរបស់អគ្គនាយក **ស.ស.ត.** ត្រូវកំណត់ដោយលក្ខន្តិកៈសហគ្រាស ដែលត្រូវស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងត្រូវស្របតាមអនុក្រឹត្យនេះ។

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក **ស.ស.ត.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា ១១ ._**

បុគ្គលិករបស់ **ស.ស.ត.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃលក្ខន្តិកៈបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ការរៀបចំលក្ខន្តិកៈបុគ្គលិកនេះ ត្រូវកំណត់កាតព្វកិច្ច និងសិទ្ធិរបស់បុគ្គលិកមានជាអាទិ៍ ការជ្រើសរើស ការវិវត្តនៃអាជីព ការបញ្ឈប់មុខងារ ការផ្តល់លាភការ ការផ្តល់អត្ថប្រយោជន៍ និងការដាក់ទណ្ឌកម្ម ព្រមទាំងត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៃនីតិការងារ។

**មាត្រា ១២ ._**

ការដឹកនាំ និងការគ្រប់គ្រងលើកិច្ចប្រតិបត្តិការអាជីវកម្ម និងការផ្តល់សេវាកម្មរបស់ **ស.ស.ត.** ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈសហគ្រាស និងលក្ខន្តិកៈបុគ្គលិក ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃសហគ្រាសសាធារណៈ។

## ជំពូកទី ៤
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រភពធនធាន

**មាត្រា ១៣ ._**

**ស.ស.ត.** ត្រូវកាន់កិច្ចបញ្ជិកាគណនេយ្យ ស្របតាមបទបញ្ញាគណនេយ្យនៃកម្ពុជា និងតាមវិធានស្តង់ដារគណនេយ្យរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល។

ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ **ស.ស.ត.** ត្រូវកំណត់រយៈពេល ១២ (ដប់ពីរ) ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់កាលបរិច្ឆេទបិទបញ្ជិកាគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។

របាយការណ៍ហិរញ្ញវត្ថុ របស់ **ស.ស.ត.** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការធ្វើសវនកម្មពីក្រសួង-ស្ថាប័នអាណាព្យាបាល និងក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១៤ ._**

យ៉ាងយូរបំផុតនៅថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំបន្ទាប់ ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការអនុម័តលើគម្រោងផែនការអាជីវកម្ម សេវាកម្ម និងវិនិយោគប្រចាំឆ្នាំ របស់ **ស.ស.ត.** តាមសំណើរបស់អគ្គនាយក។ គម្រោងផែនការអាជីវកម្ម សេវាកម្ម និងវិនិយោគប្រចាំឆ្នាំត្រូវទទួលការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការរៀបចំគម្រោងនេះ ត្រូវបញ្ចាក់ជាអាទិ៍នូវ÷

- លក្ខណៈវិនិច្ឆ័យសម្រាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ **ស.ស.ត.**
- ថវិកាសម្រាប់ដំណើរការនៃសហគ្រាស ត្រូវផ្សារភ្ជាប់នឹងស្ថានភាពអាជីវកម្ម សេវាកម្ម និងគោលដៅវិនិយោគរបស់សហគ្រាស
- គម្រោងវិនិយោគឆ្នាំនីមួយៗ ត្រូវរៀបចំស្របតាមកម្មវិធីវិនិយោគដែលបានកំណត់ទុក ស្ថានភាពរំហូរសាច់ប្រាក់ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេចកម្មវិធីវិនិយោគនេះ។

**មាត្រា ១៥ ._**

**ស.ស.ត.** មានប្រភពធនធាន ជាអាទិ៍÷

- ដើមទុនដំបូងបានមកពីថវិការបស់រដ្ឋបាលរាជធានីភ្នំពេញ ឬថវិកាជាតិ សម្រាប់វិនិយោគ និងដំណើរការគ្រប់គ្រង
- ចំណូលចរន្តពីការបង់កម្រៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ
- ចំណូលចរន្តពីការបង់កម្រៃសេវាប្រមូលកម្ទេចថ្ម ដី សំណល់គ្រឿងបរិក្ខារសង្ហារឹមចាស់ៗ សំណល់សួនច្បារ សំណល់មែកឈើ ។ល។
- ឧបត្ថម្ភធនបន្ថែមជាយថាហេតុ ពីថវិកាជាតិ
- អំណោយ និងអច្ច័យទានផ្សេងៗ
- ចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

**មាត្រា ១៦ ._**

ការបន្ថែម ឬបន្ថយដើមទុនរបស់ **ស.ស.ត.** ត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល និងមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវអនុវត្តស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រមទាំងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

**មាត្រា ១៧ ._**

ត្រូវបានដាក់ឱ្យអម **ស.ស.ត.** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំង និងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល **ស.ស.ត.** ហើយអាចពិគ្រោះ និងផ្តល់យោបល់លើចំណុចក្នុងរបៀបវារៈនៃកិច្ចប្រជុំ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

មន្ត្រីត្រួតពិនិត្យរដ្ឋអម **ស.ស.ត.** ត្រូវបំពេញការងារត្រួតពិនិត្យស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា ១៨ ._**

រយៈពេល ១៥ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល អគ្គនាយក **ស.ស.ត.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល ប្រធានស្ថាប័នអាណាព្យាបាល នូវឯកសារមានជាអាទិ៍÷

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- ថវិកាសម្រាប់ការប្រតិបត្តិការ អាជីវកម្ម សេវាកម្ម និងវិនិយោគប្រចាំឆ្នាំ
- របាយការណ៍ស្តីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ
- របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា

ចំពោះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១៩ ._**

រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ ត្រូវបន្តដំណើរការរហូតដល់ **ស.ស.ត.** ត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ។

រាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលបានរៀបចំឡើងដោយរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ ត្រូវមានអនុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ២០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |
| **សម្ដេចក្រឡាហោម ស ខេង** | អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** |

**<u>កន្លែងទទួល</u>** ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយ អាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃ**គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ** ហៅកាត់ថា **គ.ស.ហ.** ដែលជាយន្តការសម្របសម្រួលជាន់ខ្ពស់ ក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## ជំពូកទី២

## សមាសភាព

**មាត្រា២.-**

គ.ស.ហ. មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| - អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងការពារជាតិ | សមាជិក |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |
| - មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |

- អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក
- តំណាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សមាជិក
- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក
- តំណាងគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា សមាជិក
- តំណាងគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម សមាជិក
- ប្រធានក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សមាជិក
- ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លេខាធិការ។

សមាសភាពជាក់ស្តែងនៃ គ.ស.ហ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ប្រធានគ.ស.ហ.។

**មាត្រា៣.‒**

រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះត្រូវមានការទទួលខុសត្រូវក្នុងការចូលរួមប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យដែលស្ថិតក្នុងតួនាទីសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៣

## តួនាទីនិងភារកិច្ច

**មាត្រា៤.‒**

គ.ស.ហ. មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១-បង្កើតគោលនយោបាយជាតិ យុទ្ធសាស្ត្រជាតិ យន្តការសម្របសម្រួលអនុវត្តការងារនិងវាយតម្លៃហានិភ័យពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

២-ដឹកនាំនិងសម្របសម្រួលការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៣-សម្របសម្រួលការអភិវឌ្ឍប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៤-ត្រួតពិនិត្យ វាយតម្លៃអំពីប្រសិទ្ធភាពនិងវឌ្ឍនភាពនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ។

៥-តាមដាននិងវាយតម្លៃហានិភ័យពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៦-ធានាសង្គតិភាពលើគោលការណ៍និងសេចក្តីណែនាំ និងការបណ្តុះបណ្តាលរបស់ក្រសួង ស្ថាប័នត្រួតពិនិត្យពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៧-ធានាថាប្រទេសកម្ពុជាប្រតិបត្តិតាមស្តង់ដាតំបន់និងសកលលោកជាអាទិ៍៖

- សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ
- អនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ ( Financial Action Task Force )
- កាតព្វកិច្ចជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងអនុសញ្ញា សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងផែនការសកម្មភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ របស់អង្គការអន្តរជាតិ។

## ជំពូកទី៤
## កិច្ចដំណើរការការងារ

**មាត្រា៥.-**

គ.ស.ហ. ត្រូវជួបប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ដោយមានការប្រគល់សិទ្ធិពីប្រធាន។

គ.ស.ហ. ប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**មាត្រា៦.-**

គ.ស.ហ. មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជន ឬភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិនានា ដើម្បីចូលរួមពិភាក្សានិងផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ គ.ស.ហ. តាមការចាំបាច់។

**មាត្រា៧.-**

គ.ស.ហ. មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារមួយ ឬច្រើន ដើម្បីជួយ គ.ស.ហ. បំពេញការកិច្ចតាមដានវាយតម្លៃនិងសម្របសម្រួលការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ សមាជិកទាំងនោះអាចត្រូវបានជ្រើសរើសចេញពីក្រសួង ស្ថាប័នតំណាងនៅក្នុង គ.ស.ហ. និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**មាត្រា៨.-**

គ.ស.ហ. មានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាលេខាធិការដ្ឋានសម្រាប់គាំទ្រដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ស.ហ.។

**មាត្រា៩.-**

ការចំណាយលើការបំពេញតួនាទី-ភារកិច្ច និងកិច្ចដំណើរការការងាររបស់ គ.ស.ហ. ត្រូវប្រើប្រាស់កញ្ចប់ថវិការបស់ធនាគារជាតិនៃកម្ពុជា។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១០.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំង លោក **ឈន សេដ្ឋា** ជាប្រធានផ្នែកទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការ របស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន ជំនួសលោក **ស៊ីន សុជាតិ** ដែលបានលាឈប់ពីក្របខ័ណ្ឌរដ្ឋ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
